ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ : ១៨៥/១៦...ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មានកិត្តិយសសូមជម្រាបជូនម្ចាស់ ឬនាយក ឬតំណាងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងកម្មករនិយោជិតទាំងអស់ ឲ្យបានជ្រាបថា ៖ នៅពេលកម្មករនិយោជិតមានគ្រោះថ្នាក់ការងារកើតឡើងដែលប៉ះពាល់ដល់ ភ្នែក, ច្រមុះ, ត្រចៀក, បំពង់ក, មាត់ និងធ្មេញ *(ពិសេសប៉ះពាល់ដល់ភ្នែក)* ហើយមានបំណងបញ្ជូនជនរងគ្រោះទៅព្យាបាលនៅមន្ទីរពេទ្យព្រះអង្គឌួង តាមអាសយដ្ឋានផ្លូវលេខ ៥១ (មហាវិថីព្រះនរោត្តម) កែងផ្លូវលេខ១១៤ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (ដូចមានប្លង់នៅខាងខ្នងលិខិត) ។

ដើម្បីជៀសវាងការបង់ប្រាក់ជាមុនដល់មន្ទីរពេទ្យ សហគ្រាស គ្រឹះស្ថានត្រូវភ្ជាប់ *លិខិតបញ្ជូនជនរងគ្រោះដោយគ្រោះថ្នាក់ការងារ* ភ្ជាប់មកជាមួយ ធ្វើដូចទំរង់លិខិតដែលបានអនុវត្តនៅមន្ទីរពេទ្យនានាកន្លងមក ។ បេឡាជាតិរបបសន្តិសុខសង្គម នឹងទូទាត់ប្រាក់ចំណាយការព្យាបាលទាំងអស់ជាមួយមន្ទីរពេទ្យជាក្រោយ ។

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីនាយក ឬអ្នកតំណាងសហគ្រាសគ្រឹះស្ថានទាំងអស់ នឹងចូលរួមសហការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សហជីពមូលដ្ឋានតំណាងកម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ ដើម្បីឲ្យដំណើរការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ កាន់តែទទួលបាននូវប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦

**នាយក**

**អ៊ុក សមវិទ្យា**